# ដឹងឥតដង

## បទពាក្យ៧

ស្រណោះផ្លែដឹងពឹងតែដង          មុខមុតចាំចងប៉ងចាំងឈើ
ដឹងអើយនៅដងនៅគ្រាន់បើ          ពេលដងបាក់តើធ្វើយ៉ាងណា ?
ផ្លែដឹងពឹងដងប៉ងចូកចាំង          មុតគ្រប់ទីតាំងនៃកិច្ចការ
ចំណែកដឹងមនុស្សក្រៅតម្រា          ចូកចាំងពេលណាសឹងអន្តរាយ ។
ដឹងតាមតម្រាថាតាមច្បាប់          នោះសែនល្អគាប់លើសបរិយាយ
អ្នកផងសរសើរព្រោះប្រាជ្ញប្រាយ          គំនាប់អោនកាយកោតស្ញប់ស្ញែង ។
ដឹងខុសតម្រាថាតាមចិត្ត          យល់តាមគំនិតគិតម្នាក់ឯង
បកស្រាយលើកទោសគេក្តែងៗ          នោះនឹងចំបែងទៅថ្ងៃមុខ ។
អ្នកស្តាប់មិនគិតគេថាឆ្លាត          ថាប្រាជ្ញមានបាឋបទទំនុក
ថ្ងៃក្រោយគេដឹងសឹងរងទុក្ខ          អាប់យសអាប់មុខព្រោះវាចា ។
ល្ងង់ស្តាប់ហើយស្ងើចថាអ្នកចេះ          ប្រាជ្ញស្តាប់ត្រិះរិះយល់សព្វការ
អាសូរដល់ដឹងក្រៅតម្រា          ចូកចាំងចរចាថាឯងគ្រាន់ ។
ដឹងអើយដឹងមនុស្សលុះអំនួត          ដឹងប្រឹងអាងអួតដូចផ្គរលាន់
ឃើញប្លែកថាខុសដេញតាមជាន់          កំហុសរយពាន់ឃើញគ្មានសល់ ។
សប្បុរសជួយគិតកុំធ្វើហី          តើដើម្បីអ្វីគួរអោយឆ្ងល់
បើអោយខ្ញុំឆ្លើយស្តាប់ហើយឆ្ងល់          ថាគេរកខ្យល់ហាល់អវិជ្ជា ។
គេប្រឹងជំទែងលើកកំហុស          នេះខុសនោះខុសគ្រប់ច្រកទ្វារ
ចង់អោយអ្នកស្តាប់ជឿបូជា          ថាអ្នកពណ៌នាសែនប្រាជ្ញប្រាយ ។
ហេតុព្រោះក្តីខ្លៅដៅសន្តាន          ពាលនៅក្នុងប្រាណស្នានៅឆ្ងាយ
ជំទើតជំទែងស្វែងតែឆ្ងាយ          ចិត្តពាលក្នុងកាយរកមិនឃើញ ។

Ca.១៩ ឧសភា ២០០៦

ភិក្ខុ ស្វាត សាលឿម